ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ៖ ០៦៤ សជណ/គ.ជ.អ.ប

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាសម្រាប់ អនុវត្តអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ និងអនុក្រឹត្យស្តីពីការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ *១៩៣*អនក្រ.បក ចុះថ្ងៃទី *០៤* ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- យោងស្មារតីនៃកិច្ចប្រជុំលើកទី១៧របស់ គ.ជ.អ.ប. នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យអនុវត្តនូវ " **ផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ និងអនុក្រឹត្យស្តីពីការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត** " ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ ២.-**

លេខាធិការដ្ឋានគ.ជ.អ.ប. ត្រូវសម្របសម្រួល គាំទ្រ និងតាមដានលើការអនុវត្តផែនការសកម្មភាព ដូចបានកំណត់ក្នុងប្រការ១នៃសេចក្តីសម្រេចនេះ និងធ្វើសេចក្តីរាយការណ៍ជូនគ.ជ.អ.ប. ជាប្រចាំ ដើម្បីធានាការអនុវត្តឱ្យមានប្រសិទ្ធភាព។

**ប្រការ ៣.-**

រដ្ឋមន្ត្រីក្រសួងជាសមាជិកគ.ជ.អ.ប. ប្រធានលេខាធិការដ្ឋានគ.ជ.អ.ប. ក្រុមប្រឹក្សានិងគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ច័ន្ទ ១៣កើត...ខែ...មិគសិរ... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...០៩...ខែ...ធ្នូ...ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង**

**ជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**__កន្លែងទទួល__** ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាក់ព័ន្ធ
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ។

**ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០៦ ៩៧ស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៩**

**ផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ**

**និងអនុក្រឹត្យស្តីពីការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត**

| ល.រ | កិច្ចការ/សកម្មភាពសំខាន់ៗ | ២០១៩ | ២០២០ | | | | | | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | |
| **ក. ការផ្សព្វផ្សាយអនុក្រឹត្យ** | | | | | | | | | |
| ១ | ការផ្សព្វផ្សាយអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលឱ្យទៅរាជធានី ខេត្ត | √ | | | | | | | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| **ខ. ការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេស** | | | | | | | | | |
| ១ | សេចក្តីណែនាំបច្ចេកទេសស្តីពីគោលការណ៍ បែបបទ នីតិវិធី និងស្តង់ដានៃការផ្តល់សេវាតាមវិស័យនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | √ | √ | √ | √ | √ | √ | √ | ក្រសួងសាមីនីមួយៗ |
| ២ | ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាលស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្ត | √ | | | | | | | ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល |
| ៣ | ដីកាស្តីពីការធ្វើប្រតិភូកម្មមុខងារពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ | √ | | | | | | | រដ្ឋបាលរាជធានីភ្នំពេញ |
| **គ. កិច្ចការបុគ្គលិក** | | | | | | | | | |
| ១ | ការបង្កើតក្រុមការងារអន្តរក្រសួងរបស់គ.ជ.អ.ប. និងការរៀបចំគោលការណ៍ណែនាំអំពីការរៀបចំផ្ទេរបុគ្គលិក និងមុខតំណែងនានាក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | √ | | | | | | | លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២ | ការរៀបចំបញ្ជីបុគ្គលិក និងសេចក្ដីសម្រេចស្ដីពីការផ្ទេរបុគ្គលិក និងការរៀបចំមុខតំណែងនានាក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | √ | | | | | | | ក្រុមការងារអន្តរក្រសួងរបស់ គ.ជ.អ.ប. |
| ៣ | ការរៀបចំការងារបៀវត្សរ៍របស់បុគ្គលិកដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | √ | √ | | | | | | ក្រសួងមុខងារសាធារណៈ |
| ៤ | ការរៀបចំគោលការណ៍ណែនាំអំពីការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិកតាមមុខតំណែងនីមួយៗរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | | √ | √ | √ | | | | ក្រសួងមុខងារសាធារណៈ |
| ៥ | ការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិកតាមមុខតំណែងនីមួយៗ | | | | √ | √ | √ | √ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| ៦ | ប្រកាសផ្ទេរបុគ្គលិកនៃមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្ដិ៍សុខភាពទៅឱ្យរដ្ឋបាលរាជធានី ខេត្ត | √ | | | | | | | ក្រសួងមុខងារសាធារណៈ ក្រសួងសុខាភិបាល និង រដ្ឋបាលរាជធានី ខេត្ត |
| **ឃ. កិច្ចការហិរញ្ញវត្ថុ** | | | | | | | | | |
| ១ | ការកំណត់ធនធានហិរញ្ញវត្ថុ និងការរៀបចំលិខិតបទដ្ឋានសម្រាប់ផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក សម្រាប់អនុវត្តមុខងារនីមួយៗដែលបានផ្ទេរ (បន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការ និងការវិនិយោគ) | √ | √ | | | | | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ២ | ការកំណត់ធនធានហិរញ្ញវត្ថុ និងការរៀបចំលិខិតបទដ្ឋានសម្រាប់ផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលរាជធានី ខេត្តសម្រាប់អនុវត្តមុខងារក្នុងវិស័យសុខាភិបាល (បន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការ និងការវិនិយោគ) | √ | | | | | | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣ | ការសិក្សា ការពិនិត្យ និងការកែសម្រួលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | | √ | √ | √ | √ | √ | √ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **ខ. កិច្ចការទ្រព្យសម្បត្តិ** | | | | | | | | | |
| ១ | ការកំណត់ ការរៀបចំបញ្ជីទ្រព្យសម្បត្តិរបស់ក្រសួងពាក់ព័ន្ធនីមួយៗ និងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ភ្ជាប់ជាមួយមុខងារដែលបានផ្ទេរ | √ | √ | √ | √ | | | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ២ | ការកំណត់ ការរៀបចំបញ្ជីទ្រព្យសម្បត្តិរបស់ក្រសួងសុខាភិបាល និងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត | √ | √ | √ | √ | | | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **គ. កិច្ចការផែនការ** | | | | | | | | | |
| ១ | ការសិក្សា ការពិនិត្យ និងការកែសម្រួលសេចក្ដីណែនាំបច្ចេកទេសស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | | √ | √ | √ | √ | √ | √ | ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **ឃ. កិច្ចការបណ្ដុះបណ្ដាល** | | | | | | | | | |
| ១ | ការបណ្ដុះបណ្ដាលអំពីមុខងារនិងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអំពីគោលការណ៍ បែបបទ នីតិវិធីនិងស្តង់ដាផ្តល់សេវាតាមវិស័យនានាដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | √ | √ | √ | √ | √ | √ | √ | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| ២ | ការបណ្ដុះបណ្ដាលអំពីការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | √ | √ | √ | √ | √ | √ | √ | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| ៣ | ការបណ្ដុះបណ្ដាលអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានកែសម្រួល | √ | √ | √ | √ | √ | √ | √ | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| ៤ | ការបណ្ដុះបណ្ដាលអំពីសេចក្ដីណែនាំបច្ចេកទេសស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | | | | √ | √ | √ | √ | សាលាជាតិរដ្ឋបាលមូលដ្ឋាន |